ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថាបិទ

## របស់លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេស

## ក្នុងឱកាសសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៣ របស់ធនាគារជាតិនៃកម្ពុជា ស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ ភាពលានុវត្តភាព និង ហានិភ័យ"

ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅ សណ្ឋាគារ Raffles Hotel Le Royal

*************

**សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាទីមេត្រី!**

សន្និសីទរបស់យើងបានឈានមកដល់ទីបញ្ចប់ ប្រកបដោយជោគជ័យនិងផ្លែផ្កា ។ តាងនាមឲ្យធនាគារជាតិនៃកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមដ៏សកម្មរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់និងបទពិសោធន៍លើប្រធានបទរបស់សន្និសីទយើងនៅពេលនេះ ។

ដូចដែលលទ្ធផលការស្រាវជ្រាវបានបង្ហាញ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ ហើយរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសយកឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។ បច្ចុប្បន្ន វិស័យនេះកំពុងដើរតួកាន់តែសំខាន់ឡើងក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងជាបន្តបន្ទាប់នៃទ្រព្យសកម្ម ឥណទាន និងការបង្កើតការងារ ជាដើម។ ប្រធានបទទាំង៤ ដែលបានបង្ហាញក្នុងថ្ងៃនេះ បានលើកយកនូវបញ្ហា ចម្បងៗ ដែលមានសារៈសំខាន់សម្រាប់ការបន្តអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនាពេលអនាគត ហើយកិច្ចពិភាក្សា ក៏បានផ្តោតទៅលើការចែករំលែកបទពិសោធន៍ក្នុងការអនុវត្តនិងមតិនានាដែលលើកឡើងដោយភាគីពាក់ព័ន្ធចម្បងៗ ដែលក្នុងនោះរួមមាន៖ ការគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គម្លាតរវាងការផ្គត់ផ្គង់និងតម្រូវការសេវាហិរញ្ញវត្ថុ កត្តាកំណត់ឥណទានមិនដំណើរការ កម្រិតយល់ដឹងផ្នែកអាត្រាការប្រាក់របស់អតិថិជន ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាទីមេត្រី!**

ខ្ញុំជឿជាក់ថា សន្និសីទរបស់យើង បានរួមចំណែកពង្រឹងការយល់ដឹងបន្ថែមជូនអង្គសន្និសីទ ទាក់ទងនឹងការអភិវឌ្ឍនិងបញ្ហាប្រឈមក្នុងវិស័យនេះ ។ តាមរយៈការពិភាក្សា អ្នកស្រាវជ្រាវទទួលបានធាតុចូលបន្ថែម ដើម្បីធ្វើឲ្យលទ្ធផលស្រាវជ្រាវកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអាជ្ញាធរពាក់ព័ន្ធបញ្ចូលក្នុងគោលនយោបាយនិងវិធានការរបស់ខ្លួន សំដៅអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ផ្អែកលើការធ្វើបទបង្ហាញនិងកិច្ចពិភាក្សានារយៈពេលពេញមួយថ្ងៃនេះ យើងក៏បានពិនិត្យឃើញផងដែរថា មានប្រធានបទពាក់ព័ន្ធសំខាន់ៗជាច្រើនដែលគួរធ្វើការសិក្សាបន្ថែមទៀតនាពេលអនាគត ចំពោះការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ក៏ដូចជាវិស័យហិរញ្ញវត្ថុទាំងមូល ។ ក្នុងន័យនេះ ខ្ញុំសូមលើកទឹកចិត្តដល់សេដ្ឋវិទូនិងអ្នកស្រាវជ្រាវនានា ពង្រឹងនិងពង្រីកការស្រាវជ្រាវឲ្យកាន់តែស៊ីជម្រៅថែមទៀត ដើម្បីរួមចំណែកលើកកម្ពស់ការស្រាវជ្រាវនិងផ្តល់ជាធាតុចូលដល់តួអង្គពាក់ព័ន្ធសំខាន់ៗ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមក្នុងសន្និសីទថ្ងៃនេះ ។ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន ប្រាជ្ញាវាងវៃ និងមានជ័យជម្នះគ្រប់ភារកិច្ច ។

**សូមអរគុណ!**